# ១.សេចក្តីផ្តើម

## ១-១ តម្រូវការនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

១. សង្គម និងបរិស្ថានមានការផ្លាស់ប្តូរស្របគ្នាជាមួយនឹងដំណើរការនៃការអភិវឌ្ឍន៍។ ក្នុងពេលដែលការអភិវឌ្ឍន៍មានទិសដៅនាំយកមកនូវការផ្លាស់ប្តូរជាវិជ្ជមាននោះ វាក៏អាចនាំមកនូវជម្លោះផងដែរ។ នៅក្នុងបទពិសោធន៍កន្លងមកនេះ ការជំរុញនូវកំណើនសេដ្ឋកិច្ច គឺជាយន្តការមួយសំរាប់បង្កើននឹងលើកស្ទួយនូវសុខមាលភាពសង្គម។ តែកន្លងមកការអភិវឌ្ឍន៍នេះមានការយកចិត្តទុកដាក់តិចតួចអំពីផលប៉ះពាល់អវិជ្ជមានទៅលើបញ្ហាសង្គមនិងបរិស្ថាន ទើបបច្ចុប្បន្ននេះការគិតគូរអំពីផលប្រយោជន៍យូរអង្វែង បានតម្រូវអោយយើងទទួលស្គាល់នូវការអភិវឌ្ឍន៍មួយដែលមានលក្ខណៈនិរន្តភាព។ ការអភិវឌ្ឍន៍មួយដែលមានលក្ខណៈនិរន្តភាពគឺជាមូលដ្ឋានស្នូលនៃការអភិវឌ្ឍន៍ ដើម្បីធានាបាននូវសុខមាលភាពសង្គមមួយមានសមភាពសង្គម ពិតប្រាកដនិងដើម្បីបំពេញនូវរាល់សេចក្តីត្រូវការជាមូលដ្ឋានសម្រាប់មនុស្សជំនាន់ក្រោយ ។

២. ដើម្បីព្យាករណ៍អំពីផលប៉ះពាល់បរិស្ថាននិងសង្គម ដែលបង្កដោយសារការធ្វើអាជីវកម្មទាញយកផលពីធនធានរ៉ែ ដើម្បីផ្តល់នូវកាលានុវត្តភាពក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នឹងបង្កើនផលប៉ះពាល់វិជ្ជមាននោះចាំបាច់ត្រូវអនុវត្តន៍នីតិវិធីនៃការវាយតំលៃលើហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅក្នុងដំណើរការនៃការរៀបចំផែនការគ្រប់គ្រង និងផែនការអាជីវកម្មនៅក្នុងតំបន់សម្បទានរ៉ែនេះ។ ក្នុងនោះការសិក្សាអំពីផលប៉ះពាល់បានធ្វើឡើងនៅទូទាំងតំបន់សម្បទាន តែដំណោះស្រាយសង្គម (ការផ្តល់ជាប្រាក់ឧបត្ថម្ភការធ្វើបំលាស់ទី ឬការតាំងទីលំនៅសារជាថ្មី ការរៀបចំដីកាដកហូត ។ល។) អាចធ្វើឡើងមុនដំណើរការអាជីវកម្មពេញលេញ និងឬក៏ជាដំណាក់កាល១ ទៅតាមឆ្នាំអាជីវកម្មនីមួយ១ តាមកិច្ចសន្យាជាមួយគ្រួសារសហគមន៍ដែលពាក់ព័ន្ធ។

៣. ការវាយតំលៃអំពីហេតុប៉ះពាល់សង្គម គឺមានការពាក់ព័ន្ធជាមួយនឹងផលប៉ះពាល់បរិស្ថាននិងសង្គមដែលបណ្តាលមកពីការកាប់បោសសម្អាតព្រៃដើម្បីធ្វើអាជីវកម្មរ៉ែ និងការទាញយកផលមួយដែលមានលក្ខណៈនិរន្តភាពពីធនធានរ៉ែនេះតែម្តង។ ជាការពិតណាស់ដែលថា ការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គមមិនអាចដោះស្រាយនូវរាល់បញ្ហាបាននោះទេ ពីព្រោះថា ព្រឹត្តិការណ៍នេះវាជាតុល្យភាពនៃបំលាស់ប្តូររវាងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងកិច្ចការពារបរិស្ថាន ដែលតែងតែកើតមានចំពោះសកម្មភាពអភិវឌ្ឍន៍ទាំងអស់។ ប៉ុន្តែបើគ្មានកម្មវត្ថុនៃការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមទេនោះ ការសំរេចពុំអាចនឹងធ្វើទៅបានទេ ។

៤. លក្ខខ័ណ្ឌទូទៅក្នុងការធ្វើព្យាករណ៍អំពីផលវិបាកសង្គម បង្កដោយសកម្មភាពអភិវឌ្ឍន៍របស់មនុស្សនិងការរៀបចំវិធានការណ៍សមស្របមួយដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ផ្អែកលើទស្សនះវិស័យនៃការបង្កើននូវផលប៉ះពាល់វិជ្ជមាននោះមាន: (១) ការព្យាករណ៍ពីបញ្ហា (២) វិះរកវិធីសាស្ត្រដើម្បីជៀសវាង និង (៣) បង្កើននូវផលប៉ះពាល់វិជ្ជមាន។

Draft

៥. ការដែលធ្វើអោយមានផលប្រយោជន៏វិជ្ជមានច្រើនគឺជាប្រការមួយសំខាន់បំផុត។ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះផ្តល់នូវកាលានុវត្តភាពតែមួយគត់ក្នុងការបង្ហាញអំពីមធ្យោបាយ ដែលក្នុងនោះការធ្វើអោយប្រសើរឡើងនូវបរិស្ថាន និងសហគមន៍ គឺផ្នែកមួយនៃដំណើរការអភិវឌ្ឍន៏។ ម្យ៉ាងវិញទៀត ការវាយតម្លៃនេះក៏អាចព្យាករណ៏អំពីបញ្ហាជំលោះ និងឧបសគ្គ រវាងទិសដៅនៃការវិនិយោគ ស្ថានភាពបរិស្ថាន និងសហគមន៏ដែលពាក់ព័ន្ធ។ វានឹងផល់នូវកាលានុវត្តភាពសំរាប់ការរៀបចំនូវវិធានការណ៏ដើម្បីកាត់បន្ថយនូវបញ្ហាផ្សេងៗ បង្កលក្ខណៈសម្រាប់កម្មវិធីតាមដានត្រួតពិនិត្យ ដើម្បីវាយតំលៃនូវហេតុប៉ះពាល់នាពេលអនាគត និងផ្តល់នូវទិន្នន័យដែលមានសារៈសំខាន់សំរាប់ស្ថាប័នពាក់ព័ន្ធធ្វើជាមូលដ្ឋានក្នុងការសំរេច នឹងដើម្បីទប់ស្កាត់ការខូចខាតដល់បរិស្ថាន និងសង្គម ។

៦. ការវាយតំលៃអំពីផលប៉ះពាល់បរិស្ថាន និងសង្គម គឺជាឧបករណ៏គ្រប់គ្រងមួយ សំរាប់អ្នកធ្វើផែនការនឹងអ្នកផ្តល់ការអនុម័ត ជាជំនួយដល់ការសិក្សាគំរោងផ្សេងៗទៀត ជាពិសេសលើបញ្ហាវិស្វកម្ម និងសេដ្ឋកិច្ច។ បច្ចុប្បន្ននេះការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានទទួលស្គាល់ថា ជាផ្នែកយ៉ាងសំខាន់សំរាប់ការធ្វើផែនការអភិវឌ្ឍន៏ និងការគ្រប់គ្រង និងមានសារៈសំខាន់សំរាប់ការវិភាគបញ្ហាសេដ្ឋកិច្ច របស់គំរោងដូច្នេះដែរ ។

## ១-២ គោលបំណង

៧. តួនាទីចំបង និងគោលបំណងនៃការប្រើប្រាស់ដីរបស់ក្រុមហ៊ុន **Samnang Rea Thborng Thmor Import-Export and Development Co., Ltd.** គឺធ្វើយ៉ាងណាដើម្បីធានាបាននូវចិរភាពនៃការធ្វើអាជីវកម្មរ៉ែទីតានីញ៉ូមអុកសែដ។ តែទោះជាយ៉ាងនេះក្តី ព្រៃឈើក៏មានតួនាទីជាអ្នករក្សាសុវត្ថិភាព ដល់ភារៈទូទៅរបស់អេកូឡូស៊ីបរិស្ថាន និងសង្គមផងដែរ នៅពេលដែលយើងគ្រប់គ្រងបានត្រឹមត្រូវ។ ដូច្នេះគោលបំណងនៃការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមគឺ:

ក- វាយតំលៃអំពីស្ថានភាពអេកូឡូស៊ីរបស់រុក្ខជាតិក្នុងពេលបច្ចុប្បន្ន (រុក្ខជាតិ ជុល្លព្រឹក្សតិណជាតិ) ជាមួយនឹងការធ្វើសារពើភ័ណ្ឌព្រៃឈើ ។

ខ- វាយតំលៃអំពីស្ថានភាពអេកូឡូស៊ីរបស់សត្វ (ថនិកសត្វ បក្សីជាតិ និងឧរង្គសត្វ) និងជីវិតសត្វរស់នៅក្នុងទឹក (ពពួកត្រី) នៅតាមប្រព័ន្ធអូរសំខាន់ៗ។

គ- គណនាសន្និធិ កាបូនធម្មជាតិមុនពេលដំណើរការអាជីវកម្មរ៉ែ ។

ឃ- វាយតំលៃអំពីសក្តានុពលនៃការប្រើប្រាស់តំបន់ទ្រនាប់ ក្នុងនោះមានព្រៃតាមដងអូរ និងតាមចំរាក់ភ្នំចោតៗនានា។

ង- វាយតំលៃអំពីស្ថានភាពសង្គម សេដ្ឋកិច្ចរបស់សគមន៏មូលដ្ឋានក្នុងពេលបច្ចុប្បន្ន

ច- កំណត់អំពីមូលហេតុសំខាន់នានា និងកត្តាជំរុញដែលបណ្តាលអោយមានហេតុប៉ះពាល់អវិជ្ជមានរបស់គំរោងធ្វើអាជីវកម្មរ៉ែទីតានីញ៉ូមអុកស៊ែដ ទៅដល់បរិស្ថានជុំវិញ។

ឆ- កំណត់នូវវិធានការណ៍សមស្របដើម្បីលុបបំបាត់ និងឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់គំរោងធ្វើអាជីវកម្មរ៉ែទីតានីញ៉ូមអុកស៊ែដ។

## ១-៣ វិធីសាស្ត្រស្រាវជ្រាវ

៨. ដើម្បីសំរេចបាននូវគោលបំណងខាងលើ **Green Consultancy Group Co., Ltd.** បានធ្វើការវាយតំលៃដោយប្រើនូវវិធីសាស្ត្រស្រាវជ្រាវដូចមានបង្ហាញជូនខាងក្រោម៖

ក- លក្ខណៈជីវៈរូបសាស្ត្រ៖ ប្រើប្រាស់ទិន្នន័យរបស់ស្ថានីយ៍ ឧត្តុនិយម (ពោធិចិនតុង-រតនៈគីរី ២០០៣-២០០៧ និងសីតុណ្ហភាព ២០០២-២០០៩ កំពស់ទឹកភ្លៀង)។

ខ- បំរែបំរួលការប្រើប្រាស់ដី និងគំរបព្រៃ៖ ប្រើប្រាស់ទិន្នន័យ GIS & RS Datasets (UNDP GIS Datasets, 1992-93, 1997-97, FA GIS & RS Datasets 2002-2006)

គ- សារពើភ័ណ្ឌព្រៃឈើ និងធ្វើអង្កេតកាបូន៖ ដើម្បីធ្វើការប៉ាន់ស្មានអំពីសន្និធិកាបូននៅក្នុងតំបន់គំរោងរបស់ក្រុមហ៊ុន **Samnang Rea Thborng Thmor Import-Export and Development Co., Ltd.** ដែលមានភូមិសាស្ត្រស្ថិតនៅក្នុងស្រុក ថ្មបាំង និងស្រុកស្រែអំបិល ខេត្តកោះកុង។ ការធ្វើសារពើភ័ណ្ឌត្រូវបានធ្វើឡើងតាម Winrock of International of Terrestrial Carbon Measurement Standard Operating Procedures (Sarah et al, 2009)។ នៅក្នុងកំរិតនៃចំណាត់ថ្នាក់នៃការប្រើប្រាស់ដី និងគំរបព្រៃនៅក្នុងតំបន់ទីតាំង និងឡូតិ៍គំរូចំនួន ៣៨ ត្រូវបានកំណត់តាមរយៈវិធីសាស្ត្រជ្រើសរើសដោយចៃដន្យ ហើយដាក់ពង្រាយនៅទូទាំងតំបន់សម្បទាន (ឧបសម្ព័ន្ធ ១-១ ផែនទី-១ ផែនទីបង្ហាញទីតាំងឡូតិ៍គំរូពង្រាយ តាមគោលការណ៍ចៃដន្យ។ ឡូតិ៍ដែលមានរាងការេ (Nested Square Sampling Plots) ត្រូវបានប្រើប្រាស់ សំរាប់ធ្វើអង្កេតជីវម៉ាស់ ដែលលក្ខណៈជាឈើ Woody Biomass (មើលឧបសម្ព័ន្ធ១-២៖ តារាង-១៖ ទំហំ របស់ឡូតិ៍និងដើមឈើ ដែលត្រូវបានវាស់វែងនៅក្នុងឡូតិ៍គំរូនិងរូបភាព-១៖ ឡូតិ៍រាងការេ)។

ឃ- **ជីវម៉ាស់៖** របស់ឈើឈរស់ជាធម្មតាត្រូវបានធ្វើការប៉ាន់ស្មានដោយប្រើ Regression Equation នៅក្នុងទំនាក់ទំនងជាមួយ និងជីវម៉ាស់របស់ឈើដែលមានយថាប្រភេទផ្សេងៗគ្នា នៅក្នុងកំពស់ដែលមាន ១,៣ ម៉ែត្រ ពីដី (DBH at 1.3m from ground level)។ ឈើដែលមានទំហំសមស្រប ស្ថិតនៅក្នុងឡូតិ៍គំរូត្រឹមត្រូវធ្វើការវាស់វែងទាំងអស់។ ពោលគឺ ឈើដែលមានអង្កត់ផ្ចិតធំជាង ៥ស.ម ចំណែកឯឈើដែលពុក ឬវៀច កោង នៅកំពស់ ១,៣ម៉ែត្រ ការវាស់វែងត្រូវអនុវត្តន៏ទៅតាម Standard Guideline Forest Carbon Surveys (Pearson et al, 2005, Sarah, 2009)។ សារព័ន្ធរុក្ខជាតិរួមមាន ស្មៅ តិណជាតិ ជុល្លព្រឹក្ស និងរុក្ខជាតិ ដែលមានអង្កត់ផ្ចិតតូចជាង ៥ស.ម និងកំពស់ ១.៣ម ត្រូវបានរាប់ផ្សេងៗពីគ្នានៅក្នុង



Draft

ឡូតិ៍គំរូដែលមានរាងការេនេះ។ ការធ្វើអង្កេតតាមឡូតិ៍ត្រូវធ្វើឡើងទៅទិសខាងជើងក្នុងទិសដៅផ្ទុយពីទ្រនិចនាឡិកា។

**ង-  ការសិក្សាស្រាវជ្រាវពីសត្វព្រៃ:** ការស្រាវជ្រាវពីវត្តមានសត្វព្រៃត្រូវបានអនុវត្តដោយប្រើវិធីសាស្ត្រអង្កេតជាចំនុច (Point-Count) (Hostetler & main,2001)។ ការកំណត់ពីវត្តមាន និងអវត្តមានរបស់សត្វព្រៃនៅតំបន់ស្រាវជ្រាវ គឺមានសារៈសំខាន់ ដើម្បីបញ្ជាក់ពីភាពសំបូរបែប និងរបាយនៃប្រភេទសត្វព្រៃ។ រាល់ប្រភេទសត្វព្រៃទាំងអស់ជាពិសេស ថនិកសត្វ និងសត្វស្លាបត្រូវបានកត់ត្រាតាមរយៈការឮសំលេងការឃើញផ្ទាល់រួមទាំងការកត់ត្រាដានជើង និងសញ្ញាផ្សេងៗ នៅក្នុងឡូតិ៍ដែលមានរាងជារង្វង់ដែលមានកាំ២៥ម៉ែត្រ នៅក្នុងព្រៃស្រោង និងនៅក្នុងឡូតិ៍គំរូដែលមានកាំ៥០ម៉ែត្រ សម្រាប់ព្រៃល្បោះ។ រាល់ចំណុចកណ្តាលនៃឡូតិ៍សិក្សាស្រាវជ្រាវសត្វព្រៃ ត្រូវគិតចេញពីចំនុចកណ្តាលនៃឡូតិ៍ស្រាវជ្រាវរុក្ខជាតិ។ ឡូតិ៍នីមួយៗ មានចំងាយពីគ្នាយ៉ាងតិច១០០០ម៉ែត្រ ដើម្បីជៀសវាងការរាប់ពីរដង។

ច- លើសពីនេះទៅទៀត ដើម្បីឱ្យទទួលបានលទ្ធផលល្អរាល់វត្ថុតាងនានា ដែលបញ្ជាក់ពីវត្តមានសត្វព្រៃក៏ត្រូវបានធ្វើការកត់ត្រានៅពេលដែលក្រុមអ្នកស្រាវជ្រាវ ធ្វើដំណើរពីឡូតិ៍គំរូមួយទៅឡូតិ៍គំរូមួយទៀតដើម្បីឱ្យការធ្វើអត្តសញ្ញាណកម្មសត្វព្រៃកាន់តែច្បាស់។ រាល់ប្រភេទដែលពិបាកក្នុងការធ្វើអត្តសញ្ញាណកម្មដូចជាសំលេងសត្វស្លាប ឬសញ្ញាណចតុបាត (ដាន លាមក...) ក៏ត្រូវធ្វើការពិភាក្សាជាមួយអ្នកជំនួយការស្រាវជ្រាវក្នុងមូលដ្ឋានដើម្បីទទួលព័ត៌មានប្រាកដ។ លើសពីនេះក៏មានការធ្វើអត្តសញ្ញាណកម្មបន្ថែមទៀតតាមរយៈសៀវភៅសត្វស្លាបកម្ពុជា សៀវភៅថនិកសត្វកម្ពុជា ឧរង្គសត្វថៃ និងអាស៊ីអាគ្នេយ៍ និងថនិកសត្វអាស៊ីអាគ្នេយ៍។ ការសិក្សាស្រាវជ្រាវ និងការធ្វើអង្កេតនេះមិនមានការកត់ត្រាប្រភេទថនិកសត្វថ្នាក់តូចនិងពពួកថលជលិកសត្វទេ។ ការសិក្សាស្រាវជ្រាវនឹងមិនអាចធ្វើទៅ បានប្រសិនបើអាកាសធាតុមិនអំណោយផលដូចជាករណីមានភ្លៀងខ្លាំង ឬមានខ្យល់ខ្លាំងពីព្រោះលក្ខខ័ណ្ឌអាកាសធាតុ គឺជាកត្តាមួយដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការសិក្សាស្រាវជ្រាវ ជាពិសេសលើពពួកសត្វស្លាប (Hostetler& main,2001)។ ម្យ៉ាងវិញទៀតដើម្បីទទួលបានព័ត៌មានពីវត្តមាន និងរបាយសត្វព្រៃក្នុងតំបន់ស្រាវជ្រាវកាន់តែមានភាពច្បាស់លាស់នោះ ការសំភាសន៍ជាមួយប្រជាជនមូលដ្ឋានក៏ត្រូវបានអនុវត្តផងដែរ។

**ឆ-** ឧបករណ៍បច្ចេកទេសដែលប្រើរួមមានផែនទីឋានលេខាខ្នាត១:១០០០០០ ម៉ាស៊ីន GPS ផែនទីឡូតិ៍ និងគម្របព្រៃរបស់ក្រុមហ៊ុន ត្រីវិស័យ តារាងកត់ត្រាទិន្នន័យ សៀវភៅកត់ត្រា ខ្មៅដៃ ប៊ិច ខ្សែម៉ែត្រប្រវែង ៤០ ម៉ែត្រដែលមានគូសជាក្រិតក្នុងប្រវែង ១ម៉ែត្រ ៤ម៉ែត្រ និង ១០ម៉ែត្រ។ លើសពីនេះទៅទៀតម៉ែត្រ ឈើប្រវែង១ម ក៏បានប្រើផងដែរសម្រាប់វាស់ឡូតិ៍ទំហំ១ម៉ែត្រការ៉េ ដើម្បីរាប់ចំនួនប្រភេទស្មៅ និងពពួកតិណជាតិ ។



Draft

**ជ-** ការកំណត់និយមន័យពពួកស្មៅ តិណជាតិ ជុល្លព្រឹក និងប្រភេទឈើត្រូវបានពិពណ៌នាដូចខាងក្រោម:

- ❖ **ស្មៅ** : ស្ថិតនៅក្នុងថ្នាក់ម៉ូណូកូទីឡេដុង (Class Monocotyledonae) ក្នុងផ្នែក អាំងតូភីតា (Division Anthophyta) ។
- ❖ **តិណជាតិ** : គឺជាពពួករុក្ខជាតិមានផ្កាដែលដើមរបស់វាមិនមែនជាឈើ ដោយមានអាយុកាលតិចជាងមួយឆ្នាំ ឬមួយរដូវ ដោយត្រូវងាប់ជាប្រចាំឆ្នាំតាមបែបធម្មជាតិ រឺក៏ងាប់បន្ទាប់ពីចេញផ្ការួច។
- ❖ ជុល្លព្រឹក : គឺជាពពួករុក្ខជាតិដែលដើមរបស់វាមានទំរង់ជាដើមឈើ ប៉ុន្តែខុសពីតិណជាតិ។ ពពួកនេះមានសំបកជាឈើមិនមានគន្លាក់ថ្នាំងទេ។ នៅក្នុងតំបន់សិក្សាស្រាវជ្រាវ ឬស្សី ផ្តៅ រំពាក់ត្រូវបានកត់ត្រាចូលក្នុងពពួកជុល្លព្រឹកក្នុងឡូតិ៍ទំហំ ១៦ម៉ែត្រការ៉េ។
- ❖ **ដើមឈើ** : គឺជារុក្ខជាតិដែលមានគល់មួយកំណត់ច្បាស់លាស់ និងមានគំរបស្លឹក កន្សោមស្លឹក រឺឬសពិតប្រាកដ។

**ឈ- វិធីសាស្ត្រនៃការសិក្សាអំពីស្ថានភាពសង្គមសេដ្ឋកិច្ច:** ស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ ជំនាប់ ស្រុកថ្មបាំង និងឃុំ ដងពែង ស្រុកស្រែអំបិល គឺ: Qualitative Method ដោយការធ្វើ PRA ដោយការធ្វើ អត្ថាធិប្បាយសង្ខេបអំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ទៅលើបញ្ហាបរិស្ថាននិងសង្គម-សេដ្ឋកិច្ច (សមាសភាព ដែលបានចូលរួមយោបល់មាន: អភិបាល អភិបាលរងខេត្ត ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និង ថាមពល ប្រធាន មន្ទីរកសិកម្ម ប្រធានមន្ទីរបរិស្ថាន នាយខណ្ឌរដ្ឋបាលព្រៃឈើខេត្តកោះកុង តំណាងអង្គការ WildAid តំណាងក្រុមហ៊ុន **Samnang Rea Thborng Thmor Import-Export and Development Co., Ltd.** អភិបាលស្រុកថ្មបាំង អភិបាលស្រុកស្រែអំបិល មេឃុំ សមាជិកឃុំ ស្មៀនឃុំ ក្រុមប្រឹក្សា អភិវឌ្ឍន៍ឃុំ មេភូមិ អនុភូមិ ដែលរស់នៅក្នុងតំបន់ គំរោងជាច្រើននាក់ (តារាងទី៩-១ បានធ្វើឡើងនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៩ និង៩-២ ថ្ងៃទី ០៣-០៨ ខែ តុលា ឆ្នាំ ២០០៩។ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៩ ក្រុមការងារបានរៀបចំ កិច្ចប្រជុំដើម្បីធ្វើបទបង្ហាញលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ចុងក្រោយជាមួយថ្នាក់ដឹកនាំខេត្តស្រុក និងប្រធានមន្ទីរជំនាញដែលពាក់ព័ន្ធនឹងគំរោង (តារាង៩-១) ដើម្បីផ្លាស់ប្តូរយោបល់បន្ថែមលើរបាយការណ៍វាយតម្លៃនេះ (មើលកំណត់ហេតុស្តីពីការធ្វើបទបង្ហាញរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់គំរោងស្រាវជ្រាវនឹងធ្វើ អាជីវកម្មរ៉ែ Ilmenite) សូមអាននៅទំព័រ១២៦-១៤៣។

**៩.** ការអង្កេតនេះបានធ្វើឡើងនៅទីវាលលើកទី-១ នៅ ថ្ងៃទី ២១-២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ និងលើកទី-២ ពីថ្ងៃទី ៥-៩ ខែ មេសា ឆ្នាំ ២០១០។ និងបន្តធ្វើសំយោគទិន្នន័យនៅក្នុង Computer ដោយប្រើប្រាស់ Software Microsoft Word and Excel ។

## ១-៤ ភាពជឿជាក់

### ១-៤-១ ការផ្តល់ប្រឹក្សានៅមូលដ្ឋាន

១០. នៅក្នុងរយៈពេលនៃការសិក្សា និងវាយតម្លៃ នៅក្នុងតំបន់សម្បទានរ៉ែទីតានីញ៉ូមឌីអុកស៊ីដនេះ ប្រធានក្រុមការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម បានចុះពិនិត្យផ្ទាល់ ដើម្បីធានាបានថាការពិនិត្យ វាយតម្លៃ និងការប្រមូលពត៌មាន និងទិន្នន័យបានធ្វើទៅតាមគោលការណ៍ណែនាំ និងវិធីសាស្ត្រស្រាវជ្រាវ ។

### ១-៤-២ ក្រុមការងារ IEIA

១១. ក្រុមការងារ IESIA មានចំនួន១០នាក់ ដូចមានរាយនាមខាងក្រោម:

| | | | |
|---|---|---|---|
| ១- | បណ្ឌិត | លី សុពណ៌-មុនី | D.V.M., Post Ph.D |
| ២- | អនុបណ្ឌិត | តេង ប៉េងសៀង | GIS & RS Specialist |
| ៣- | បរិញ្ញាត្រី | ឡៅ សារុន | អ្នកប្រមូលទិន្នន័យផ្នែកសង្គម-សេដ្ឋកិច្ច |
| ៤- | លោក | ពៅ សោមាណាក់ | ប្រធានក្រុម និងដឹកនាំការងារនៅទីវាល |
| ៥- | លោក | ហេង ណាំយី | អ្នកជំនាញសត្វព្រៃ និងរុក្ខជាតិ |
| ៦- | លោក | ហេង សុករិទ្ធ | អ្នកជំនាញសត្វព្រៃ និងរុក្ខជាតិ |
| ៧- | លោក | អេងប៊ុឡូ | អ្នកជំនាញសត្វព្រៃ |
| ៨- | លោក | ស៊ាង គឹមហៃ | ជំនួយការស្រាវជ្រាវ |
| ៩- | លោក | ធី | ជំនួយការស្រាវជ្រាវ |
| ១០- | លោក | អ៊ាប សួយ | ជំនួយការស្រាវជ្រាវ |
| ១១- | លោក | អ៊ាប សួង | ជំនួយការស្រាវជ្រាវ |
| ១២- | លោក | សុខ សៀន | ជំនួយការស្រាវជ្រាវ |
| ១៣- | លោក | យឹម ឃឿន | ជំនួយការស្រាវជ្រាវ |
| ១៤- | លោក | ឡុង ខឿន | ជំនួយការស្រាវជ្រាវ |
| ១៥- | លោក | អាត | ជំនួយការស្រាវជ្រាវ |

Draft